ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

* * *

ឆ្នាំទី ៣ លេខ១២.១៣ថ្ងៃទី ១៥ ខែ មេសា ឆ្នាំ ១៩៩៥

រាជកិច្ច

រួមមានៈ

- ច្បាប់
- ក្រម- ក្រឹត្យ
- អនុក្រឹត្យ
- ប្រកាស
- សេចក្តីសំរេច
- សារាចរ

ផ្សាយចេញពីទីស្តីការគណៈរដ្ឋមន្ត្រីរៀងរាល់សប្តាហ៍

មាតិកា

I - ធីស្ដីការគណៈរដ្ឋមន្ត្រី

១.អនុក្រឹត្យ

២-៤-១៩៩៥ - អនុក្រឹត្យលេខ ៣៦ អនក្រ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិអចិន្ត្រៃយ៍ ប្រឡងប្រឡងប្រណាំង តែលំអសោភភាពខេត្ត ក្រុង ទូទាំងប្រទេស ៥១៥

៤-៤-១៩៩៥ - អនុក្រឹត្យលេខ ៣៧ អនក្រ ស្ដីពីការបង្កើតគណៈកម្មការនៃការថែទាំសុខភាពបឋម ៥១៧

៤-៤-១៩៩៥ - អនុក្រឹត្យលេខ ៤១ អនក្រ ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៥១៩

៤-៤-១៩៩៥ - អនុក្រឹត្យលេខ ៤២ អនក្រ ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៥២០

៤-៤-១៩៩៥ - អនុក្រឹត្យលេខ ៤៣ អនក្រ ស្ដីពីការជូនមេដាយស្ថាបនាជាតិ ៥២១

១៣-៤-១៩៩៥ - អនុក្រឹត្យលេខ ៤៤ អនក្រ ស្ដីពីការតែងតាំងមន្ត្រីរាជការ ៥២៣

២. សេចក្ដីសំរេច

១០-៤-១៩៩៥ - សេចក្ដីសំរេចលេខ ៣៥ សសរ ស្ដីពីការបង្កើតគណៈកម្មការពិសេស សំរាប់រៀបចំសិក្ខាសាលា ស្ដីពីតួនាទី និង សមត្ថកិច្ចរបស់ខេត្ត-ក្រុង ដើម្បីអនុវត្តនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល ៥២៤

II- ការងារបណ្ដាក្រសួង

១. ធីស្ដីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

១២-៤-១៩៩៥ - ប្រកាសលេខ ០៧៦ សហវ ប្រកប ស្ដីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ ៥២៧

៣. ទីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

៤-៤-១៩៩៥ - ប្រកាសលេខ ២៨៥ ផកប្រក អនុញ្ញាតអោយអ្នកស្រី ម៉ុ ឡេង ជនជាតិខ្មែរ
បើកដំណើរការផលិតនំប៉័ង ៥២៨

៤-៤-១៩៩៥ - ប្រកាសលេខ ២៨៦ ផកប្រក អនុញ្ញាតអោយលោក ណៃ នីម ជនជាតិខ្មែរ
បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ ៥២៨

៤-៤-១៩៩៥ - ប្រកាសលេខ ២៨៧ ផកប្រក អនុញ្ញាតអោយលោក អ៊ុ ហៀង ជនជាតិខ្មែរ
បន្តដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ១៨ សេះ ៥២៩

៤-៤-១៩៩៥ - ប្រកាសលេខ ២៨៨ ផកប្រក អនុញ្ញាតអោយអ្នកស្រី នាង ឃីម ជនជាតិខ្មែរ
បន្តដំណើរការជាងក្រឡឹងដែក ៥២៩

៤-៤-១៩៩៥ - ប្រកាសលេខ ២៨៩ ផកប្រក អនុញ្ញាតអោយលោក ស៊ិន ហាន ជនជាតិខ្មែរ
បន្តដំណើរការរោងហជាងជួសជុលម៉ាញ៉េ និង ទូរទស្សន៍........................ ៥២៩

៤-៤-១៩៩៥ - ប្រកាសលេខ ២៩០ ផកប្រក អនុញ្ញាតអោយលោក ផា សុខ ជនជាតិខ្មែរ
បើកដំណើរការរោងម៉ាស៊ីនកិនស្រូវកំលាំង ៨០ សេះ ៥៣០

៤-៤-១៩៩៥ - ប្រកាសលេខ ២៩១ ផកប្រក អនុញ្ញាតអោយអ្នកស្រី សុខ ចាន់ ជនជាតិខ្មែរ
បើកសហគ្រាសផលិតគ្រឿងសង្ហារិម " យូ អាន តេង " YU AN TENG ៥៣០

៤-៤-១៩៩៥ -ប្រកាសលេខ ២៧៧ ផក.ប្រក អនុញ្ញាតអោយលោក ឡាយ ឃិនពីរ ជនជាតិ ខ្មែរ
បើកដំណើរការរោងជាងក្រឡឹងដែក និង ជួសជុលយន្ត........................ ៥៣១

៤-៤-១៩៩៥ - ប្រកាសលេខ ២៧៨ ផកប្រក អនុញ្ញាតអោយលោក ទេព សុវត្ថិ ជនជាតិខ្មែរ
បើកដំណើរការសិប្បកម្មផលិតទឹកត្រីទន្លេសាប សញ្ញា " រូបត្រីពីរ " ៥៣២

៤-៤-១៩៩៥ - ប្រកាសលេខ ២៧៩ ផកប្រក អនុញ្ញាតអោយអ្នកស្រី ង៉ី វី ជនជាតិខ្មែរ
បើកដំណើរការឧស្សាហកម្មតូច ផលិតទឹកបរិសុទ្ធសញ្ញា " មីណេរ៉ាល់ K " ៥៣២

៤-៤-១៩៩៥ - ប្រកាសលេខ ២៨០ ផកប្រក អនុញ្ញាតអោយលោក តាត់ សារុធ ជនជាតិខ្មែរ បើកដំណើរការសិប្បកម្មកាត់ដេរសំលៀកបំពាក់ ៥៣៣

៤-៤-១៩៩៥ - ប្រកាសលេខ ២៨១ ផកប្រក អនុញ្ញាតអោយលោក ង៉ូវ ប៉ែត ជនជាតិខ្មែរ បើកដំណើរការសិប្បកម្មបណ្តុះមេផ្សិត ៥៣៣

៤-៤-១៩៩៥ - ប្រកាសលេខ ២៨២ ផកប្រក អនុញ្ញាតអោយលោក ផុក គួន ជនជាតិខ្មែរ បើកដំណើរការសិប្បកម្មកាត់ដេរសំលៀកបំពាក់ ៥៣៤

៤-៤-១៩៩៥ - ប្រកាសលេខ ២៨៣ ផកប្រក អនុញ្ញាតអោយលោក ស្រ៊ិន ហ៊ីម ជនជាតិខ្មែរ បើកដំណើរការឧស្សាហកម្មតូចផលិតទឹកកកដើម................................ ៥៣៤

៤-៤-១៩៩៥ - ប្រកាសលេខ ២៨៤ ផកប្រក អនុញ្ញាតអោយលោក នូវ ឌិសថ ជនជាតិខ្មែរ បើកដំណើរការសិប្បកម្មផលិតទឹកត្រី ខេអរៈសច្ឆាសញ្ញា “ នាគកំពត ”...... ៥៣៤

៧-៤-១៩៩៥ - ប្រកាសលេខ ២៨៥ ផកប្រក អនុញ្ញាតអោយលោក សៀង ហុក ជនជាតិខ្មែរ បើកដំណើរការសហគ្រាសកែច្នៃ ឥរ និង ផ្តៅ “ រតនគិរី ” ៥៣៥

៧-៤-១៩៩៥ - ប្រកាសលេខ ២៨៦ ផកប្រក អនុញ្ញាតអោយលោក ឈៀង ប៊ុនហ៊ុម ជនជាតិខ្មែរ បើកដំណើរការខេស្សាហកម្មតូចផលិតការ៉េមបៀក និង ទឹកកកដើម........ ៥៣៦

៧-៤-១៩៩៥ - ប្រកាសលេខ ២៨៧ ផកប្រក អនុញ្ញាតអោយលោក ឡេា សុភ័ក្រ ជនជាតិខ្មែរ បន្តដំណើរការឧស្សាហកម្មតូច ផលិតទឹកកកអនាម័យ ៥៣៦

៧-៤-១៩៩៥ - ប្រកាសលេខ ២៨៨ ផកប្រក អនុញ្ញាតអោយលោក នង កែម ជនជាតិខ្មែរ បើកដំណើរការម៉ាស៊ីនកិនស្រូវកំលាំង ១២ សេះ................................ ៥៣៧

១២-៤-១៩៩៥ - ប្រកាសលេខ ៣០០ ផកប្រក អនុញ្ញាតអោយលោក យូ ហួ ជនជាតិខ្មែរ បើកដំណើរការផលិតកម្មសហគ្រាសផលិតគ្រឿងសង្ហារិម ហាសហ៊ុល អ៊ិនទែណាស្យូណាល់.. ៥៣៧

៣- ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

៣-៤-១៩៩៥ - ប្រកាសលេខ ០៨៨/៩៥ ពម.ប្រក ស្តីពីការអនុញ្ញាតអោយអ្នកស្រី ប៉ៅ ណារ៉េត បើកអាជីវកម្មទូរទស្សន៍ខ្សែកាប ៥៣៨

៥-៤-១៩៩៥ - ប្រកាសលេខ ០៨៥/៩៥ ពម.ប្រក ស្តីពីការអនុញ្ញាតអោយអ្នកស្រី ហាស ប៉េងជួ បើកអាជីវកម្មរោងពុម្ព ដែលមានឈ្មោះ " ចន្ទ្រះ " ៥៣៩

១១-៤-១៩៩៥ - ប្រកាសលេខ ០៩០/៩៥ ពម.ប្រក ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការរបស់មន្ត្រីរាជការ ៥៤០

៤- ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ប្រកាស

៣-៤-១៩៩៥ - ប្រកាសលេខ ១៨៥ ប្រក.កសក.ធត ស្តីពីការផ្ទេរការិយាល័យបូកសរុប ពីមន្ទីរទៅនាយកដ្ឋានផែនការស្ថិតិ ៥៤១

៥- ទីស្តីការរដ្ឋមន្ត្រី ក្រសួងទេសចរណ៍

ប្រកាស

១១-៤-១៩៩៥ ប្រកាសលេខ ៤១១ កទធ ស្តីពីការតែងតាំងជាបណ្តោះអាសន្ន ចំពោះមន្ត្រីថ្នាក់អនុប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប ៥៤២

៦- ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

ប្រកាស

៥-៤-១៩៩៥ - ប្រកាសលេខ ២១៨ អយក.ប្រក ស្តីពីការផ្ទេរវិទ្យាល័យកលព្រឹក្ស ពីឧបសម្ព័ន្ធវិទ្យាគងពិសី ហើយប្តូរឈ្មោះវិទ្យាល័យកលព្រឹក្ស ជាវិទ្យាល័យព្រះនរោត្តមរណឫទ្ធិ ៥៤៤

១០-៤-១៩៩៥ - ប្រកាសលេខ ២៣២ អយក.ប្រក ស្តីពីការបង្រួមអនុវិទ្យាល័យសន្តិភាព និងវិទ្យាល័យតាខ្មៅ ស្រុកតាខ្មៅ ខេត្ត កណ្តាល ៥៤៥

៧- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ

សេចក្តីសំរេច

៥-៤-១៩៩៥ - សេចក្តីសំរេចលេខ ២៣៣ សសរ.បស.ប្រខ ស្តីពីការបែងចែកសិស្សនិស្សិតចំនួន ១០៨១ ដែលទើបបញ្ចប់ការសិក្សាក្នុងប្រទេស ៥៤៦

I- ទីស្ដីការគណៈរដ្ឋមន្ត្រី

១. អនុក្រឹត្យ

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៣៦ អនក្រ
ស្ដីពីការបង្កើតគណៈកម្មាធិការជាតិអចិន្ត្រៃយ៍
ប្រឡងប្រណាំងកែលំអសោភ័ណភាព ខេត្ត-ក្រុង
ទូទាំងប្រទេស

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្ដេចព្រះ នរោត្ដម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-យោងតាមសារាចរលេខ ០២ ស.រ ចុះថ្ងៃទី ០៩ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ស្ដីពីការប្រឡងប្រណាំងកែលំអសោភ័ណភាព ខេត្ត-ក្រុង ទូទាំងប្រទេស

សំរេច

មាត្រា ១ : បង្កើតគណៈកម្មាធិការជាតិអចិន្ត្រៃយ៍ប្រឡងប្រណាំងកែលំអសោភ័ណភាព ខេត្ត-ក្រុង ទូទាំងប្រទេស ដែលមានសមាសភាពដូចតទៅ ÷

១- ឯកឧត្ដម សហរដ្ឋមន្ត្រី ក្រសួងមហាផ្ទៃ	សហប្រធាន
២- ឯកឧត្ដមរដ្ឋលេខាធិការ ទីស្ដីការគណៈរដ្ឋមន្ត្រី	អនុប្រធានអចិន្ត្រៃយ៍
៣- ឯកឧត្ដមរដ្ឋមន្ត្រី ក្រសួងអភិវឌ្ឍន៍ជនបទ	សមាជិក
៤- ឯកឧត្ដមរដ្ឋលេខាធិការ ក្រសួងទេសចរណ៍	សមាជិក
៥- ឯកឧត្ដមអនុរដ្ឋលេខាធិការ ក្រសួងគ្រប់គ្រងបរិស្ថាន	សមាជិក

៦- ឯកឧត្តមអនុរដ្ឋលេខាធិការ ក្រសួងសាធារណការនិងដឹកជញ្ជូន	សមាជិក
៧- ឯកឧត្តមអនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល	សមាជិក
៨- ឯកឧត្តមអនុរដ្ឋលេខាធិការ ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ	សមាជិក
៩- ឯកឧត្តមអភិបាលគ្រប់ខេត្ត-ក្រុង	សមាជិក
១០-លោកប្រធាននាយកដ្ឋានប្រលងប្រណាំង ទីស្តីការគណៈរដ្ឋមន្ត្រី	លេខាធិការ

មាត្រា ២ : គណៈកម្មាធិការជាតិនេះមានភារកិច្ចដូចខាងក្រោម ÷

-កសាងលក្ខខ័ណ្ឌនានាសំរាប់ការវាស់ស្ទង់ និង ផ្តល់ពិន្ទុដល់ការងារប្រលងប្រណាំងទូទាំងប្រទេស ។

-ពិនិត្យតាមដាន វាយតំលៃនូវលទ្ធផលប្រឡងប្រណាំងដែលខេត្ត-ក្រុង សំរេចបាន ។

-កសាងសំណុំលិខិតលើកសំណើជូនរាជរដ្ឋាភិបាល ដើម្បីផ្តល់គ្រឿងឥស្សរិយយស និង រង្វាន់ផ្សេងៗក្នុងការងារនេះ ។

-ប្រជុំបូកសរុបរបាយការណ៍របស់ខេត្ត-ក្រុង ប្រចាំឆមាសនិងឆ្នាំ ហើយរាយការណ៍ជូនគណៈរដ្ឋមន្ត្រីព្រមជាមួយ នេះរៀបចំបើកសន្និបាតប្រចាំឆ្នាំ បូកសរុបស្នាដៃ និង លើកពិសោធន៍គំរូសំរាប់ទិសដៅនាឆ្នាំខាងមុខ ។

គណៈកម្មាធិការជាតិ មានសិទ្ធិបែងចែកតំបន់ប្រឡងប្រណាំងក្នុងព្រះរាជាណាចក្រកម្ពុជា និងមានសិទ្ធិបង្កើតលេខាធិការដ្ឋានអចិន្ត្រៃយ៍ដើម្បីជួយការងារ ។

មាត្រា ៣ : សមាជិកគណៈកម្មាធិការជាតិ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន និង មានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងមហាផ្ទៃ ។

មាត្រា ៤ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រី រដ្ឋលេខាធិការនៃគ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ និង ឯកឧត្តម-អស់លោក ដែលមានឈ្មោះក្នុងមាត្រា ១ ត្រូវអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្ថលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្ថលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៣៧ អនក្រ
ស្តីពីការបង្កើតគណៈកម្មការ
នៃការថែទាំសុខភាពបឋម

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- តាមសំណើរបស់រដ្ឋមន្ត្រី ក្រសួងសុខាភិបាល

សំរេច

មាត្រា ១ : បង្កើតគណៈកម្មការអន្តរក្រសួងមួយ ដែលមានឈ្មោះថា “ គណៈកម្មការអន្តរក្រសួងនៃការ ថែទាំសុខភាពបឋម ” ដើម្បីគ្រប់គ្រង និងអនុវត្តកម្មវិធីថែទាំសុខភាពបឋម អោយមានប្រសិទ្ធភាព ។

មាត្រា ២ : គណៈកម្មការនៃការថែទាំសុខភាពបឋមមានសមាសភាពដូចខាងក្រោម ÷

១_ឯកឧត្តមរដ្ឋមន្ត្រីក្រសួងសុខាភិបាល	ប្រធាន
២_ឯកឧត្តមរដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ	អនុប្រធាន
៣_ឯកឧត្តមរដ្ឋលេខាធិការក្រសួងអប់រំយុវជននិងកីឡា	សមាជិក
៤_ឯកឧត្តមរដ្ឋលេខាធិការ ក្រសួងកសិកម្ម	សមាជិក
៥_ឯកឧត្តមរដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ	សមាជិក
៦_ឯកឧត្តមរដ្ឋលេខាធិការ ក្រសួងសង្គមកិច្ចការងារ និងអតីតយុទ្ធជន	សមាជិក
៧_ឯកឧត្តមអនុរដ្ឋលេខាធិការ ក្រសួងហិរញ្ញវត្ថុ និងសេដ្ឋកិច្ច	សមាជិក
៨_លោកជំទាវអនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានកិច្ចការនារី	សមាជិក
៩_លោកតំណាងកាកបាទក្រហមកម្ពុជា	សមាជិក

១០_លោកអភិបាលរងខេត្ត_ក្រុង និង រាជធានីភ្នំពេញ សមាជិក

មាត្រា ៣ : គណៈកម្មការអន្តរក្រសួងនៃការថែទាំសុខភាពបឋម ត្រូវមានលេខាធិការដ្ឋានមួយ ជាជំនួយការ ដែលមានសមាសភាពដូចខាងក្រោមនេះ ÷

- ឯកឧត្តមអនុរដ្ឋលេខាធិការ ក្រសួងសុខាភិបាល ប្រធាន
- ឯកឧត្តមអនុរដ្ឋលេខាធិការ ក្រសួងអភិវឌ្ឍន៍ជនបទ អនុប្រធាន
- លោកប្រធាននាយកដ្ឋានថែទាំសុខភាពបឋម ក្រសួងសុខាភិបាល សមាជិកអចិន្ត្រៃយ៍
- លោកតំណាងក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក
- មន្ត្រីរាជការសុខាភិបាល ៤ រូប សមាជិក

មាត្រា ៤ : គណៈកម្មការអន្តរក្រសួង នៃការថែទាំសុខភាពបឋម មានទីតាំងអចិន្ត្រៃយ៍របស់ខ្លួននៅក្នុងទីស្តីការ រដ្ឋមន្ត្រីក្រសួង សុខាភិបាល ហើយមានសិទ្ធិប្រើប្រាស់ត្រារបស់ក្រសួងសុខាភិបាល ។

មាត្រា ៥ : គណៈកម្មការអន្តរក្រសួងនៃការថែទាំសុខភាពបឋម មានភារកិច្ចដូចតទៅ ÷

១_ធានាការយល់ដឹងអំពីខ្លឹមសារបច្ចេកទេស និងគោលនយោបាយថែទាំសុខភាពបឋម ដោយមាន ការតំរង់ទិសពីក្រសួងសុខាភិបាល មុនពេលចាប់អនុវត្តនូវគំរោងការ និងកម្មវិធីថែទាំសុខភាព បឋម ។

២_ប្រមូល និងចងក្រងពត៌មាន អំពីកម្មវិធី និងគំរោងការទាំងអស់ក្នុងការផ្តល់ការថែទាំសុខភាព បឋម ដែលកំពុងអនុវត្តនៅកម្ពុជា ។

៣_លើកទឹកចិត្តអោយមានសហប្រតិបត្តិការទៅវិញទៅមក ក្នុងការថែទាំសុខភាពបឋមនៅមូលដ្ឋាន និងជៀសវាង កិច្ចខិតខំប្រឹងប្រែងជាន់គ្នា ។

៤_ត្រួតពិនិត្យគុណភាព សកម្មភាពនៃការថែទាំសុខភាពបឋម ដែលផ្តល់ជូនជនកម្ពុជាគ្រប់រូប រាប់ទាំងស្ត្រី កុមារ និងបុរស ។

៥_លើកសំណើជូនរាជរដ្ឋាភិបាលនូវមធ្យោបាយ :

- ជួយប្រជារាស្ត្រអោយមានលទ្ធភាពទទួលនូវកម្មវិធីថែទាំសុខភាពបឋម
- ចលនាប្រភពធនធានតាមរយៈសប្បុរសជន និងអង្គការអន្តរជាតិនានា សំរាប់សេវាថែ ទាំសុខភាពបឋម ។

លេខាធិការដ្ឋាន មានភារកិច្ចដូចតទៅ :

១_អញ្ជើញគណៈកម្មការចូលរួមប្រជុំ និងតំកល់ទុកឯកសារ និងរបាយការណ៍ផ្សេងៗ

២_តាមដានការអនុវត្តសេចក្តីសំរេច និងមតិណែនាំផ្សេងៗ របស់គណៈកម្មការអន្តរក្រសួង ។ ធ្វើរបាយការណ៍ជូន ទៅរាជរដ្ឋាភិបាល អំពីការអនុវត្តការងារថែទាំសុខភាពបឋមនៅទូទាំងប្រទេស ។

៣_ផ្តល់ការណែនាំបច្ចេកទេស ដើម្បីអោយគ្រប់ស្ថាប័ន និងអង្គការនានាមានការយល់ដឹងអំពីគោលនយោបាយ និងយុទ្ធសាស្ត្រសុខាភិបាល ព្រមទាំងគោលការណ៍ និងខ្លឹមសារនៃការងារថែទាំសុខភាពបឋម ។

៤_សហប្រតិបត្តិការជិតស្និទ្ធជាមួយអង្គការសុខភាពពិភពលោក យូនីសែហ្វ , យូអិនឌីភី , មេឌីកាម , អង្គការអន្តរជាតិ និងអង្គការមិនមែនរដ្ឋាភិបាលនានា ដើម្បីជួយឧបត្ថម្ភថវិកា និងបច្ចេកទេសដល់ការងារថែទាំសុខភាពបឋម ។

មាត្រា ៦ : ស្ថាប័ន និងក្រសួងពាក់ព័ន្ធ ក្នុងការងារថែទាំសុខភាពបឋម គប្បីចាត់តាំងក្រុមបង្គោលមួយសំរាប់គណៈកម្មការ ឬ លេខាធិការដ្ឋានខាងការថែទាំសុខភាពបឋម ដើម្បីធានានូវសកម្មភាព និងការផ្តត់ផ្គង់របាយការណ៍ទៀងទាត់ ។

មាត្រា ៧ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសុខាភិបាល សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអប់រំយុវជន និងកីឡា បណ្តាស្ថាប័ន និងអភិបាលខេត្ត-ក្រុង ដែលមានការពាក់ព័ន្ធ ព្រមទាំងឯកឧត្តម អស់លោក ដែលមាននៅក្នុងមាត្រា ២ និង មាត្រា ៣ មានភារកិច្ចអនុវត្តអនុក្រឹត្យនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៤១ អនក្រ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

_បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើ ដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតនិងប្រើប្រាស់មេដាយស្ថាបនាជាតិ និង ប័ណ្ណស្ថាបនាជាតិ

-តាមសំណើរបស់អភិបាលខេត្ត កំពង់ស្ពឺ

សម្រេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ជូនចំពោះលោក **ស៊ិន សុខា** និង អ្នកស្រី **កាន់ ផល្លី** ម្ចាស់សណ្ឋាគារ តុសិតពៃទូរ្យ ដែលបានចំណាយទ្រព្យធនផ្ទាល់ខ្លួនកសាងវិទ្យាល័យ មួយ នៅខេត្តកំពង់ស្ពឺ អស់ទឹកប្រាក់ចំនួន ១១៩.០០០ ដុល្លាអាមេរិក ។

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកំពង់ស្ពឺ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

***

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៤២ អនក្រ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្តីពីការបង្កើតនិងប្រើប្រាស់មេដាយស្ថាបនាជាតិ និង ប័ណ្ណស្ថាបនាជាតិ

-តាមសំណើរបស់ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រីទី ២

សំរេច

មាត្រា ១ ៖ ត្រូវបានប្រគល់មេដាយស្ថាបនាជាតិថ្នាក់លេខ ១ ជូនចំពោះសប្បុរសជនដែលមានសទ្ធាជ្រះថ្លា បានបរិច្ចាគអំណោយជួយដល់ប្រជារាស្ត្រក្រីក្រ នៅខេត្តតាកែវ ដូចមាននាមខាងក្រោមនេះ ÷

១-ក្រុមហ៊ុន **ភាពីម៉ិច** ក្រមា ២.០០០ សារុង ២.០០០ និង ប្រាក់ ២០ លានរៀល

២-លោកស្រី **សោម សុផល** អង្ករ ៤០ តោន

មាត្រា ២ ៖ សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលលទ្ធផលល្អប្រសើរ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៤៣ អនក្រ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-បានឃើញអនុក្រឹត្យលេខ ១៥ អនក្រ ចុះថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៤ របស់រាជរដ្ឋាភិបាល ស្ដីពីការបង្កើត និង ប្រើប្រាស់មេដាយស្ថាបនាជាតិ និង ប័ណ្ណស្ថាបនាជាតិ

-តាមសំណើរបស់ខុទ្ទកាល័យសម្ដេចនាយករដ្ឋមន្ត្រីទី ២

សំរេច

មាត្រា ១ : ត្រូវបានប្រគល់មេដាយស្ថាបនាជាតិ តាមលំដាប់ថ្នាក់ជូនចំពោះសប្បុរសជនដែលមានសទ្ធាជ្រះថ្លា បានបរិច្ចាគទ្រព្យសម្បត្តិផ្ទាល់ខ្លួន ផ្ដល់ជាអំណោយដល់ប្រជារាស្ត្ររងគ្រោះនៅស្រុកបវេល ខេត្តបាត់ដំបង ដូចមានរាយនាមខាងក្រោមនេះ :

ក/មេដាយស្ថាបនាជាតិថ្នាក់លេខ ១ :

១-ក្រុមហ៊ុន **ម៉ែន សារុន** អង្ករ ១៣០ តោន និង ប្រាក់ ១៥ លានរៀល

២-ក្រុមហ៊ុន **ភាពីម៉ិច** និង **ហាសីបកឹប** ក្រមា ១៥០០ សារុង ១៥០០ និងប្រាក់ ៤៣ លានរៀល

៣-ក្រុមហ៊ុន **ថាយហ៊្គឹរ** ប្រាក់ ៤១ លានរៀល

៤-លោក **គង់ ទ្រឹម** ប្រាក់ ៤០ លានរៀល

៥-ក្រុមហ៊ុន **សូគីម៉ិច** ប្រាក់ ៣០ លានរៀល

ខ/ មេដាយស្ថាបនាជាតិថ្នាក់លេខ ២ :

១-សមាគមព្រះបរមគ្រូ **ឈឹម ហាយ** ប្រាក់ ២៤ លានរៀល

២-លោក **គីម ហាប់** ប្រាក់ ២០ លានរៀល

៣-ក្រុមហ៊ុន **ឌីយ៉ាម៉ង់** ប្រាក់ ១៥ លានរៀល

៤-ក្រុមហ៊ុន **ថៃ ប៊ុនរ៉ុង** ប្រាក់ ១៣ លានរៀល

៥-ឯកឧត្តម **ញឹម វណ្ណដា** និងលោកជំទាវ សារុង ២.០០០ និង ក្រមា ២.០០០

គ/ មេដាយស្ថាបនាជាតិថ្នាក់លេខ ៣ :

១-ក្រុមហ៊ុន **ជី ម៉ិច** ប្រាក់ ១០ លានរៀល

២-លោក និង លោកស្រី **ចាន់ សារុន** ប្រាក់ ០៧ លានរៀល

៣-ក្រុមហ៊ុន **គ្រុប លីហេង** ប្រាក់ ០៥ លាន ០២ សែនរៀល

៤-ឧត្តមសេនីយ៍ **ម៉ា ឈឿន** និង លោកស្រី **អ៊ុក ម៉ាលី** ប្រាក់ ០៥ លានរៀល

៥-ក្រុមហ៊ុន **ឡុង ឈឹម** ប្រាក់ ០៥ លានរៀល

៦_លោក **អ៊ឹយ សឹម** សណ្ឋាគារឌីយ៉ាម៉ង់ ប្រាក់ ០៤ លានរៀល

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រីត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

នាយករដ្ឋមន្ត្រីទី ១	នាយករដ្ឋមន្ត្រីទី ២
ព្រះហស្តលេខានិងត្រា	ហត្ថលេខានិងត្រា
នរោត្តម រណឫទ្ធិ	**ហ៊ុន សែន**

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១៣ ខែ មេសា ឆ្នាំ ១៩៩៥

អនុក្រឹត្យលេខ ៤៤ អនក្រ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-តាមសំណើរបស់ឯកឧត្តមរដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សំរេច

មាត្រា ១ : តែងតាំង :

១_លោក **ណា ម៉ារឌី** ជាប្រធានក្រុមហ៊ុនចំការកៅស៊ូមេមត់

២_លោក **សៀក ពិសិដ្ឋ** ជាប្រធានក្រុមហ៊ុនចំការកៅស៊ូក្រែក

៣_លោក **ហេង សារ៉ាក** ជាប្រធានក្រុមហ៊ុនចំការកៅស៊ូស្នួល

មាត្រា ២ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ និង

សាមីជនដែលមានចែងក្នុងមាត្រា ១ ត្រូវទទួលអនុវត្តតាមអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និង ចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ១ នាយករដ្ឋមន្ត្រីទី ២

ព្រះហស្តលេខានិងត្រា ហត្ថលេខានិងត្រា

នរោត្តម រណឫទ្ធិ **ហ៊ុន សែន**

***

២. សេចក្តីសំរេច

រាជធានីភ្នំពេញ , ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ៣៥ សសរ
ស្តីពីការបង្កើតគណៈកម្មការពិសេសសំរាប់រៀបចំសិក្ខាសាលា ស្តីពីតួនាទី និង សមត្ថកិច្ចរបស់ខេត្ត-ក្រុង ដើម្បីអនុវត្តនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ចុះថ្ងៃទី ១៩ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤

-យោងតាមសំណូមពរការងារចាំបាច់

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការពិសេសមួយសំរាប់រៀបចំសិក្ខាសាលា ស្តីពីតួនាទី និងសមត្ថកិច្ចរបស់ខេត្ត-ក្រុង ដើម្បីអនុវត្តនយោបាយអភិវឌ្ឍន៍របស់រាជរដ្ឋាភិបាលដែលមានសមាសភាពដូចខាងក្រោម ÷

១-ឯកឧត្តម សហរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ប្រធាន

២-ឯកឧត្តម រដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ អនុប្រធាន

៣_ឯកឧត្តម អគ្គលេខាធិការ ក.អ.ភ អនុប្រធាន

៤_ឯកឧត្តមតំណាង ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិកអចិន្ត្រៃយ៍

៥_ឯកឧត្តមតំណាង ក្រសួងការពារជាតិ សមាជិក

៦_ឯកឧត្តមតំណាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ សមាជិក

៧_ឯកឧត្តមតំណាង ក្រសួងសុខាភិបាល សមាជិក

៨_ឯកឧត្តមតំណាង ក្រសួងសាធារណការ និង ដឹកជញ្ជូន សមាជិក

៩_ឯកឧត្តមតំណាង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក

១០_ឯកឧត្តមតំណាង ក្រសួងទេសចរណ៍ សមាជិក

១១_ឯកឧត្តមតំណាង ក្រសួងផែនការ សមាជិក

១២_ឯកឧត្តមតំណាង ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល សមាជិក

១៣_ឯកឧត្តម ជុំ ប៊ុនរ៉ុង ទីប្រឹក្សាសម្តេចនាយករដ្ឋមន្ត្រីទី ២ សមាជិក

១៤_ឯកឧត្តម អគ្គលេខាធិការក្រុមប្រឹក្សា ស្តារអភិវឌ្ឍន៍វិស័យកសិកម្ម និង ជនបទ សមាជិក

១៥_ឯកឧត្តម ខួវ ម៉េងហ៊ាង ទីប្រឹក្សាសម្តេចក្រុមព្រះ សមាជិក

ប្រការ ២ : គណៈកម្មការពិសេសនេះ មានភារកិច្ចរៀបចំកម្មវិធី និង ខ្លឹមសារអត្ថបទសំរាប់សិក្ខាសាលា ដែលមានប្រធាន បទ :

-" សន្តិសុខ និង ស្ថេរភាពដើម្បីការអភិវឌ្ឍន៍ "

-ពាក្យស្លោក " រាស្ត្រមានមុនរដ្ឋ " ជាក់ឆ្លងមតិសម្តេចនាយករដ្ឋមន្ត្រី ទាំងពីរ ។

ប្រការ ៣ : ដើម្បីបង្កលក្ខណៈងាយស្រួល ដល់គណៈកម្មការពិសេសនេះអោយដំណើរការបានល្អ និងទាន់ពេលវេលា សមាជិកនិមួយៗមានភារកិច្ចដូចខាងក្រោមនេះ ÷

-ឯកឧត្តមសហរដ្ឋលេខាធិការក្រសួងមហាផ្ទៃ ត្រូវចាត់ចែងអោយក្រុមជំនាញក្រោមឱវាទក្រសួង ធ្វើសេចក្តីព្រាងខ្លឹមសារនៃប្រធានបទ " សន្តិសុខ និង ស្ថេរភាពដើម្បីការអភិវឌ្ឍន៍ " ។

-ឯកឧត្តមរដ្ឋលេខាធិការក្រសួងអភិវឌ្ឍន៍ជនបទ និង អគ្គលេខាធិការ ក.អ.ភ សហការ ចាត់ចែង ក្រុមការងារក្រោមឱវាទធ្វើសេចក្តីព្រាង នៃប្រធានបទជាពាក្យស្លោក " រាស្ត្រមានមុនរដ្ឋ " ។

-ឯកឧត្តមតំណាង ក្រសួងទេសចរណ៍ ចាត់ចែងក្រុមការងារក្រោមឱវាទ ធ្វើសេចក្តីព្រាងនៃទិសដៅ និង អត្ថប្រយោជន៍របស់វិស័យទេសចរណ៍តាមបណ្តា ខេត្ត-ក្រុង

-ឯកឧត្តមតំណាង ទីស្តីការគណៈរដ្ឋមន្ត្រី រៀបចំកម្មវិធីបើកសិក្ខាសាលា និង កម្មវិធីប្រជុំរបស់គណៈកម្មការពិសេស និង តាមដានការងារ ។

-ឯកឧត្តម ជាសមាជិកដទៃទៀត មានភារកិច្ចជួយកែសំរួលខ្លឹមសារប្រធានបទ សំរាប់សិក្ខាសាលា និងកម្មវិធីបើកសិក្ខាសាលាអោយបានដំណើរការប្រកបដោយជោគជ័យ និង សុវត្ថិភាព ។

ប្រការ ៤ : គណៈកម្មការនេះ ត្រូវចូលរួមប្រជុំ និងបំពេញភារកិច្ចតាមសេចក្តីអញ្ជើញ និងតាមការណែនាំរបស់ប្រធានគណៈកម្មការពិសេសនេះ ។

ប្រការ ៥ : គណៈកម្មការនេះ នឹងត្រូវរំសាយជាស្វ័យប្រវត្តិ ក្រោយពីសិក្ខាសាលាបានដំណើរការចប់សព្វគ្រប់ហើយ ។

ប្រការ ៦ : កិច្ចរៀបចំធ្វើសិក្ខាសាលានេះត្រូវបានកំណត់ និង ធ្វើអោយហើយនៅជំណាច់ខែមេសា ។

ប្រការ ៧ : ក្រសួងមហាផ្ទៃ ត្រៀមរៀបចំសន្និបាត នៅពាក់កណ្តាលខែ ឧសភា ។

ប្រការ ៨ : សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអភិវឌ្ឍន៍ជនបទ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា រដ្ឋមន្ត្រីក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីក្រសួងផែនការ រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង សាមីខ្លួនត្រូវអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខា និងចុះហត្ថលេខាតទៅ ។

នាយករដ្ឋមន្ត្រីទី ២

ហត្ថលេខា និង ត្រា

ហ៊ុន សែន

* * *

II . ការងារបណ្តាក្រសួង

១. ទីស្តីការរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ប្រកាស

រាជធានីភ្នំពេញ ថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៧៦ សហវ.ប្រក.ប
ស្តីពីការផ្ទេរក្របខ័ណ្ឌមន្ត្រីរាជការ

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល កម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញព្រះរាជក្រឹត្យ នស.រកត ១០៩៤.០៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាព រាជរដ្ឋាភិបាល
- បានឃើញលិខិតលេខ ៣១៨លស.ពល ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការទទួលយកលោក **សុខ សារឿន** មន្ត្រីគណៈកម្មាធិការអធិការកិច្ចហិរញ្ញវត្ថុ ឋានៈអនុប្រធាននាយកដ្ឋាននៃក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
- តាមសំណើរបស់នាយកដ្ឋានបុគ្គលិក

សំរេច

មាត្រា ១ : ផ្ទេរក្របខ័ណ្ឌលោក **សុខ សារឿន** មន្ត្រីគណៈកម្មាធិការអធិការកិច្ចហិរញ្ញវត្ថុ ឋានៈអនុប្រធាននាយកដ្ឋាននៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ អោយទៅបំរើការងារនៅទីស្តីការគណៈរដ្ឋមន្ត្រី ។

មាត្រា ២ : ប្រាក់បៀវត្សនិងប្រាក់ឧបត្ថម្ភផ្សេងៗរបស់សាមីខ្លួន ត្រូវបើកនៅទីស្តីការគណៈរដ្ឋមន្ត្រី បន្ទាប់ពីមានវិញ្ញាបនប័ត្រ ផ្ទេរប្រាក់របស់ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ។

មាត្រា ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានបុគ្គលិក ប្រធានគណៈកម្មាធិការអធិការកិច្ចហិរញ្ញវត្ថុ និង អង្គភាពពាក់ព័ន្ធព្រមទាំង សាមីខ្លួន ដូចក្នុងមាត្រា ១ ខាងលើ ត្រូវអនុវត្តតាមប្រកាសនេះ ។

ហត្ថលេខា និង ត្រា

គាត ឈន់

២. ធីស្តីការរដ្ឋមន្ត្រីក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល

ប្រកាស

ប្រកាសលេខ ២៨៥ ឧក.ប្រក ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ អ្នកស្រី ម៉ី ឡេង ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៩៨៧៣៩ ក.៣ចុះថ្ងៃទី ០៩_៣_៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៦៤ អ៊ី០ ផ្លូវលេខ ១៣០ក្រុមទី ១៦ សង្កាត់ ផ្សារចាស់ ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ បើកដំណើរការ ឡផលិតនំប៉័ង នៅក្នុងទីតាំង ផ្ទះលេខ ៤៨ អ៊ី០ ផ្លូវលេខ ១១០ ក្រុមទី ០៧ សង្កាត់ ផ្សារកណ្តាលទី ១ ខ័ណ្ឌ ដូនពេញរាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៨៦ ឧក.ប្រក ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ លោក ណី ទីម ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៨៦៦៨២ ៣.ស ចុះថ្ងៃទី ២២_៣_៨៩ អាសយដ្ឋានបច្ចុប្បន្ន ក្រុមទី ៨ ភូមិ រំលេច ឃុំ រំលេច ស្រុកបាកាន ខេត្ត ពោធិសាត់ បើកដំណើរ ការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋានខាងលើ ។

ប្រការ ២ : លោក ណី ទីម ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម_ អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវ ទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៨៧ ផក.ប្រក ចុះថ្ងៃទី 0៤ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ រោងម៉ាស៊ីនកិនស្រូវដែលមានលោក ស៊ិន ទន់ ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណ លេខ ០៨៥៦៩៣ ព.ស ចុះថ្ងៃទី ២៣_៣_៨៩ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៦ ភូមិ ស្អកខ្លា ឃុំ រំលេច ស្រុក បាកាន ខេត្ត ពោធិសាត់ បើកដំណើរការ ផលិតកម្ម ដោយប្រើម៉ាស៊ីន កំលាំង ៨0 សេះ នៅក្នុងទីតាំង ក្រុមទី ៤ ភូមិ ខ្វាវ ឃុំ រំលេច ស្រុក បាកាន ខេត្ត ពោធិសាត់ ។

ប្រការ ២ : លោក ស៊ិន ទន់ ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវ ទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៨៨ ផក.ប្រក ចុះថ្ងៃទី 0៤ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ អ្នកស្រី នាង យ៉ិម ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៩៧០៤៣ ភ.ព ចុះថ្ងៃទី ០៩_០២_៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១០ អឺ១ ផ្លូវលេខ ១១៨ ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ បន្តដំណើរការ រោងជាងក្រឡឹងដែក នៅក្នុងទីតាំង ផ្ទះលេខ ៧ អា ផ្លូវលេខ ១០៣ ក្រុមទី ២៩ សង្កាត់ បឹងកេងកង ២ ខ័ណ្ឌ ចំការមន រាជធានីភ្នំពេញ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៨៩ ផក.ប្រក ចុះថ្ងៃទី 0៤ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ លោក ស៊ិន ហាន ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១៤៣៦៦៩ ភ.ព ចុះថ្ងៃទី ០៧_៣_៨៩ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៣៥៦ អា ផ្លូវ ព្រះមុនីវង្ស ក្រុមទី

១៩ សង្កាត់ បឹងកេងកងទី ១ ខ័ណ្ឌ ចំការមន រាជធានីភ្នំពេញ បើកដំណើរការ រោងជាងជួសជុលម៉ាញ៉េ និង ទូរទស្សន៍ នៅក្នុងទីតាំង ដូចអាស័យដ្ឋាន ខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៩០ ផក.ប្រក ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ លោក ផា សុខ ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៨០៩១៩ ព.ស ចុះថ្ងៃទី ០៥-៣-៨៩ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៣ ភូមិ មេទឹក ឃុំ មេទឹក ស្រុក បាកាន ខេត្ត ពោធិសាត់ បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ៨០ សេះ នៅក្នុងទីតាំង ក្រុមទី ៤ ភូមិ បឹងឈូក ឃុំ ខ្នារទទឹង ស្រុក បាកាន ខេត្ត ពោធិសាត់ ។

ប្រការ ២ : លោក ផា សុខ ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ដោយធានានូវ ទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៩១ ផក.ប្រក ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ សហគ្រាសផលិតគ្រឿងសង្ហារិម " យូ-អាន-តេង YU_AN TENG " ដែលអ្នកស្រី សុខ ចាន់ ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៦៨០១៦ ភ.ព ចុះថ្ងៃទី ១៥-២-១៩៨៥ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៤០ បេអឺ០ហៀត ផ្លូវលេខ ២២៨ ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ បើកដំណើរការ ផលិតកម្ម នៅក្នុងទីតាំង ផ្ទះលេខ ១៥៩៣ ផ្លូវជាតិលេខ ២ ភូមិ ទទូលគោ សង្កាត់ ចាក់អង្រែក្រោម ខ័ណ្ឌ មានជ័យ រាជធានីភ្នំពេញ ។

ប្រការ ២ ៖ អ្នកស្រី សុខ ចាន់ ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ គិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។

ប្រការ ៣ ៖ ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់សហគ្រាសត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិដ្ឋាន ធានាគុណភាពផលិតផល និង គោរពរាល់ច្បាប់បញ្ញាតិ ដែលមានជាធរមាន ។

ប្រការ ៤ ៖ សហគ្រាសនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវន្តៈ គ្រោងទ្វារ-បង្អួច ក្តារការ៉ូ បង្កាន់ដៃឈើ តុ ទូ កៅអី ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតកម្ម គឺ ឈើដែលមានលក្ខណៈស្របច្បាប់ ។

ប្រការ ៥ ៖ ម្ចាស់សហគ្រាសត្រូវធ្វើរបាយការណ៍ប្រចាំខែ អំពីសកម្មភាពផលិតកម្មរបស់សហគ្រាស ជូនអេកក្រសួងតាមរយៈមន្ទីរឧស្សាហកម្មរ៉ែ និង ថាមពលរាជធានីភ្នំពេញ ។

ប្រការ ៦ ៖ ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ២៧៧ ឧក.ប្រក ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១ ៖ អនុញ្ញាតអោយ លោក ឡាយ យិនពីវ ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ៣២៣៩៨៥ ក.រ ចុះថ្ងៃទី ១៥-៥-៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១២០ ផ្លូវជាតិលេខ ៤ ភូមិព្រៃព្រីងខាងជើង សង្កាត់ ចោមចៅ ខ័ណ្ឌ ដង្កោ រាជធានីភ្នំពេញ បើកដំណើរការរោងជាងក្រឡឹងដែក និង ជួសជុលរថយន្ត នៅក្នុងទីតាំង ដូចអាស័យដ្ឋាន ខាងលើ ។

ប្រការ ២ ៖ ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ២៧៨ ផក.ប្រក ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ លោក ទេព សុវុត ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣៧០៨៦ ក.រ ចុះថ្ងៃទី ១៨-១១-៩៣ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៥ ផ្លូវលេខ ៥៥៦ ក្រុមទី ៣៣ សង្កាត់ បឹងកក់ទី ១ ខ័ណ្ឌ ទួលគោក រាជធានីភ្នំពេញ បើកដំណើរការ សិប្បកម្ម ផលិតទឹកត្រីទន្លេសាបសញ្ញា " រូបត្រីពីរ " នៅក្នុងទីតាំង ដូចអាស័យដ្ឋាន ខាងលើ ។

ប្រការ ២ : លោក ទេព សុវុត ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម- អាជីវកម្ម នូវមុខផលិតផលទឹកត្រីទន្លេសាបសញ្ញា " រូបត្រីពីរ " ស្របតាមគំរូ និង ផ្លាកសញ្ញាដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំ ការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៧៩ ផក.ប្រក ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ អ្នកស្រី ង៉ី វី ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ៣១៣២១៧ ក.រ ចុះថ្ងៃទី ១២-៣-៩២ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៩០ អឺ០ ផ្លូវលេខ ១៣២ ក្រុមទី ៨ សង្កាត់ ទឹកល្អក់ទី ១ ខ័ណ្ឌ ទួលគោក រាជធានីភ្នំពេញ បើកដំណើរការ ឧស្សាហកម្មតូច ផលិតទឹកបរិសុទ្ធសញ្ញា " មីណេរ៉ាល់ K " នៅក្នុងទីតាំង ភូមិព្រែកតាទែន ឃុំ ព្រែកតាទែន ស្រុក ពញាឮ ខេត្តកណ្តាល ។

ប្រការ ២ : អ្នកស្រី ង៉ី វី ត្រូវរៀបចំឧស្សាហកម្មតូចផលិតទឹកបរិសុទ្ធរបស់ខ្លួនអោយរួចស្រេចជាស្ថាពរ ក្នុងរយៈពេល បី ខែ គិតចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ហួសពេលកំណត់ប្រកាសនេះត្រូវចាត់ទុកជាមោឃៈ ។

ប្រការ ៣ : អ្នកស្រី ង៉ី វី ត្រូវផលិតនូវមុខផលិតផល ទឹកបរិសុទ្ធ " មីណេរ៉ាល់ K " ស្របតាមគំរូ និង ផ្លាកសញ្ញាដែលបាន តំកល់ទុកនៅក្រសួងឧស្សាហកម្មរ៉ែ និង ថាមពល ។

ប្រការ ៤ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៨០ ជក.ប្រក ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ លោក តាត់ សាវុធ ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៧៩៥៣៣ ភ.៣ ចុះថ្ងៃទី ១៦_៣_៨៥ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ២៨៨ អឺ០ ផ្លូវលេខ ២១៧ សង្កាត់ អូរឫស្សីទី ២ ខណ្ឌ ៧មករា រាជធានីភ្នំពេញ បើកដំណើរការ សិប្បកម្មកាត់ដេរសំលៀកបំពាក់ នៅក្នុងទីតាំង ដូចអាស័យដ្ឋាន ខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៨១ ជក.ប្រក ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ លោក ង៉ូវ ប៉ែត ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១៩១៥០៧៣ ភ.៣ ចុះថ្ងៃទី ១៥_៥_៨៨ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៤៧ អឺ០ ផ្លូវលេខ ២០៦ ក្រុមទី ៥៤ សង្កាត់ ផ្សារដើមគរ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ បើកដំណើការ សិប្បកម្មបណ្តុះមេផ្សិត នៅក្នុងទីតាំង ដូចអាស័យដ្ឋាន ខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៨២ ផក.ប្រក ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ លោក ផុក ធួន ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ០៤៩៧០០ ក.ព ចុះថ្ងៃទី ២៥-០១-៨៥ អាសយដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១២៦ ផ្លូវ កែវម៉ានី សង្កាត់ ទួលទំពូងទី ១ ខ័ណ្ឌ ចំការមន រាជធានីភ្នំពេញ បន្តដំណើរការ សិប្បកម្មកាត់ដេរសំលៀកបំពាក់ នៅក្នុងទីតាំង ដូចអាសយដ្ឋាន ខាងលើ ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៨៣ ផក.ប្រក ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ លោក ស្រ៊ុន ឃីម ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០៦៨៣៩៥ ក.ច ចុះថ្ងៃទី ១៨-១-៨៧ អាសយដ្ឋានបច្ចុប្បន្ន ភូមិ ព្រៃកពោធិក្រោម ឃុំ ព្រៃកពោធិ ស្រុក ស្រីសន្ធរ ខេត្ត កំពង់ចាម បើកដំណើរការ ឧស្សាហកម្មតូច ផលិតទឹកកកដើម នៅក្នុងទីតាំង ភូមិ ទួរឈើ ឃុំ ព្រែកពោធិ ស្រុក ស្រីសន្ធរ ខេត្ត កំពង់ចាម ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៨៤ ផក.ប្រក ចុះថ្ងៃទី ០៤ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ លោក សួន ឱសថ ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ១៨៣០៩៤ ក.ណ ចុះថ្ងៃទី ២៨-៧-៨៨ អាសយដ្ឋានបច្ចុប្បន្ន ភូមិ អរិយក្សត្រ ឃុំ អរិយក្សត្រ ស្រុក ល្វាឯម ខេត្ត កណ្ដាល បើកដំណើរការ សិប្បកម្ម ផលិតទឹកត្រី មានម៉ាក សញ្ញា “ នាគ-កំពត ” នៅក្នុងទីតាំង ដូចអាសយដ្ឋាន ខាងលើ ។

ប្រការ ២ : លោក សួន ឱសថ ត្រូវរៀបចំសិប្បកម្មផលិតទឹកត្រីរបស់ខ្លួនអោយរួមស្រេចជាស្ថាពរ ក្នុងរយៈពេល បី ខែយ៉ាងយូរ គិតចាប់តាំងពីថ្ងៃចុះហត្ថលេខានេះតទៅ ហួសពេលកំណត់ប្រកាសនេះត្រូវចាត់ទុកជាមោឃៈ ។

ប្រការ ៣ : លោក សួន ឱសថ ត្រូវផលិតនូវមុខផលិតផល ទឹកត្រីខេមរៈមច្ឆា សញ្ញា " នាគ_កំពត " ស្របតាមគំរូ និង ផ្លាក សញ្ញាដែលបានតំកល់ទុកនៅក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ។

ប្រការ ៤ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៩៥ ផក.ប្រក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ លោក សៀង ហុក ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ៣២៦២៩៩ ភ.៣ ចុះថ្ងៃទី ៣១_១២_៩១ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ១៤ អឺ០ ផ្លូវលេខ ២៩៤ ក្រុមទី ៦៩ សង្កាត់ បឹងកេងកងទី ១ ខ័ណ្ឌ ចំការមន រាជធានីភ្នំពេញ បើកដំណើរការ សហគ្រាស កែច្នៃ តរ និងត្បូង " រតនៈគិរី " នៅក្នុងទីតាំង ភូមិ ទី ១ ឃុំ ចំការកៅស៊ូ ស្រុក បានលុង ខេត្ត រតនៈគិរី ។

ប្រការ ២ : លោក សៀង ហុក ត្រូវចាប់ផ្តើមដំណើរការផលិតកម្ម_ អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ក្នុងរយៈពេល ០៦ ខែ គិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។ ហួសកាលកំណត់ប្រកាសនេះទុកជាមោឃៈ ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់សហគ្រាសត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិដ្ឋាន ធានាគុណភាពផលិតផល និង គោរពរាល់ច្បាប់បញ្ញត្តិដែលមានជាធរមាន ។

ប្រការ ៤ : ម្ចាស់សហគ្រាសត្រូវជូនដំណឹងមកក្រសួងតាមរយៈមន្ទីរឧស្សាហកម្មរ៉ែ និង ថាមពល ខេត្ត រតនៈគិរី អំពីកាលបរិច្ឆេទ នៃ ការចាប់ផ្តើមដំណើរការជាផ្លូវការ និង របាយការណ៍ប្រចាំខែ អំពីសកម្មភាពផលិតកម្មរបស់ សហគ្រាស ។

ប្រការ ៥ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

***

ប្រកាសលេខ ២៩៦ ឧក.ប្រក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ លោក ឃៀង ប៊ុនហ៊ុម ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ០២០១៣៥ បប. ចុះថ្ងៃទី ២៧-៣-៨៦ អាស័យដ្ឋានបច្ចុប្បន្ន ក្រុមទី ៣១ ភូមិ វត្តលៀប សង្កាត់ ចំការសំរោង ទីរួមខេត្ត បាត់ដំបង ខេត្ត បាត់ដំបង បើកដំណើរការ ឧស្សាហកម្មតូច ផលិតការ៉េមបៀក និង ទឹកកក ដើម នៅក្នុងទីតាំង ក្រុមទី ៣២ ភូមិ វត្តលៀប សង្កាត់ ចំការសំរោង ទីរួមខេត្ត បាត់ដំបង ខេត្ត បាត់ដំបង ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ២៩៧ ឧក.ប្រក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ លោក ឡា សុភ័ក្រ ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណលេខ ១៩២៦១៤ ភ.ព ចុះថ្ងៃទី ២៣-៨-៨៨ អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៥៣ បេអឺ0 ផ្លូវលេខ ១៨០ ក្រុមទី ២៩ សង្កាត់ បឹងរាំង ខណ្ឌ ដូនពេញ រាជធានីភ្នំពេញ បន្តដំណើរការ ឧស្សាហកម្មតូច ផលិតទឹកកកអនាម័យ " សហហ្វាមចំកាត់ " នៅក្នុងទីតាំងដីឡូត៍គ្មានលេខ ផ្លូវលេខ ២១១ ភូមិ ព្រែកសំរោង សង្កាត់ សេរីភាព ទីរួមខេត្ត កណ្តាល ខេត្ត កណ្តាល ។

ប្រការ ២ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ផលិតផលគ្មានគុណភាពប៉ះពាល់ដល់សុខភាពប្រជារាស្ត្រ ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

ប្រកាសលេខ ២៩៨ ផក.ប្រក ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ លោក នង កែម ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណប័ណ្ណ លេខ ៨០៦១៧៣ ក.ណ ចុះថ្ងៃទី ១៥-៥-៨៤ អាស័យដ្ឋានបច្ចុប្បន្ន ភូមិ ព្រាំងរលួស ឃុំ របាំងកែន ស្រុក កណ្ដាលស្ទឹង ខេត្ត កណ្ដាល បើកដំណើរការ រោងម៉ាស៊ីនកិនស្រូវ កំលាំង ១២ សេះ នៅក្នុងទីតាំង ដូចអាស័យដ្ឋាន ខាងលើ ។

ប្រការ ២ : លោក នង កែម ត្រូវចាប់ផ្ដើមដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ដោយធានានូវ ទិន្នផលអង្ករលេខ ១ អោយបានយ៉ាងតិចបំផុត ៦៥ ភាគរយ ។

ប្រការ ៣ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការ អនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដក ហូតវិញដោយគ្មានសំណងឡើយ ។

* * *

ប្រកាសលេខ ៣០០ ផក.ប្រក ចុះថ្ងៃទី ១២ ខែ មេសា ឆ្នាំ ១៩៩៥

ប្រការ ១ : អនុញ្ញាតអោយ សហគ្រាសផលិតគ្រឿងសង្ហារិម ហស ហ៊ីល អ៊ិនទែរណាស្យូណាល់ HORSE HILL INTERNATIONAL ដែល មានលោក យូ ហូ ជនជាតិ ខ្មែរ សញ្ជាតិ កម្ពុជា កាន់អត្តសញ្ញាណ ប័ណ្ណលេខ ២៩១៥២៩ ក.ព ចុះថ្ងៃទី ២៥-០៥-៩២ ជាប្រធាន អាស័យដ្ឋានបច្ចុប្បន្ន ផ្ទះលេខ ៥៩ ផ្លូវលេខ ៥៣ សង្កាត់ ផ្សារថ្មីទី ១ ខ័ណ្ឌ ដូនពេញ រាជធានីភ្នំពេញ បើកដំណើរការ ផលិតកម្ម នៅក្នុងទីតាំង ភូមិ ក្បាលដំរី សង្កាត់ កាកាប ខ័ណ្ឌ ដង្កោ រាជធានីភ្នំពេញ ។

ប្រការ ២ : លោក យូ ហូ ត្រូវចាប់ផ្ដើមដំណើរការផលិតកម្ម- អាជីវកម្ម លើទីតាំងដែលបានកំណត់ក្នុងប្លង់ ក្នុងរយៈពេល ០៦ ខែ គិតចាប់តាំងពីថ្ងៃដែលបានចុះហត្ថលេខាលើប្រកាសនេះ ។ ហួសកាលកំណត់ ប្រកាសនេះត្រូវទុកជាមោឃៈ ។

ប្រការ ៣ : ក្នុងកិច្ចដំណើរការផលិតកម្ម ម្ចាស់សហគ្រាសត្រូវធានាសុវត្ថិភាពឧស្សាហកម្ម ធានាបរិដ្ឋាន ធានាគុណភាពផលិតផលនិង គោរពរាល់ច្បាប់បញ្ញត្តិ ដែលមានជាធរមាន ។

ប្រការ ៤ : សហគ្រាសនេះត្រូវបានអនុញ្ញាតអោយផលិតនូវមុខផលិតផលជាសារវន្តៈ ឈើស៊ុមទ្វារ សន្លឹកទ្វារ ឈើក្រឡឹង ក្តារតាប៉ូ ក្តារប៉ាឡែត តុ ទូ កៅអី គ្រែ និង ក្តារម្ល៉ូស ។ វត្ថុធាតុដើមដែលយកមកប្រើប្រាស់ក្នុងផលិតកម្ម គឺ ឈើដែល មានលក្ខណៈស្របច្បាប់ ។

ប្រការ ៥ : ម្ចាស់សហគ្រាសត្រូវជូនដំណឹងមកក្រសួងតាមរយៈមន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល រាជធានីភ្នំពេញ អំពីកាលបរិច្ឆេទ នៃការចាប់ផ្តើមដំណើរការជាផ្លូវការ និង ធ្វើរបាយការណ៍ប្រចាំខែអំពីសកម្មភាពផលិតកម្មរបស់ សហគ្រាស ។

ប្រការ ៦ : ប្រកាសនេះមានតំលៃក្នុងរយៈពេល បី ឆ្នាំ ។ ផុតកំណត់ពេលនេះ ម្ចាស់មូលដ្ឋានត្រូវធ្វើពាក្យសុំការអនុញ្ញាតបន្តផលិតកម្មរបស់ខ្លួនឡើងវិញ ។ ក្នុងករណីប្រព្រឹត្តល្មើសច្បាប់ ប្រកាសនេះនឹងត្រូវដកហូតវិញដោយគ្មានសំណងឡើយ ។

រដ្ឋមន្ត្រី
ហត្ថលេខា និង ត្រា
ពូ សុធីរៈ

***

៣- ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៤៨/៩៥ ពម.ប្រក

រដ្ឋមន្ត្រី ក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាចុះថ្ងៃទី ០១-១១-៩៣
- យោងតាមការឯកភាពរបស់អភិបាលខេត្ត កំពត លេខ ១៣១ លចប.កព ចុះថ្ងៃទី ២៥-០១-៩៥
- ពិនិត្យលើសំណើអនុញ្ញាតច្បាប់បើកអាជីវកម្មទូរទស្សន៍តាបរបស់អ្នកស្រី ម៉ៅ ណារ៉េត ចុះថ្ងៃទី ២៩-០៣-៩៥

សំរេច

ប្រការ ១ : អនុញ្ញាតអោយអ្នកស្រី **ម៉ៅ ណារ៉េត** ប្រជាពលរដ្ឋនៅភូមិទី ១ ឃុំ កំពង់កណ្តាល ស្រុក កំពង់បាយ ខេត្តកំពត បើកអាជីវកម្មទូរទស្សន៍ខ្សែកាប សំរាប់បន្តជាវអោយអតិថិជន នៅស្រុក កំពង់បាយ ខេត្ត កំពត ។

ប្រការ ២ : សាម៉ីខ្លួនត្រូវអនុវត្តអោយបានសមស្របតាមនោលការណ៍ច្បាប់រដ្ឋកំណត់ និង ទទួលការណែនាំផ្ទាល់ ពីមន្ទីរពត៌មានខេត្តកំពត ហើយត្រូវគោរពតាមកិច្ចសន្យា និងលក្ខន្តិកៈ ដែលបានបញ្ចូលមកក្រសួង ពត៌មាន និង ហាមប្រើប្រព័ន្ធនេះ ដើម្បីធ្វើនយោបាយ និង ពាណិជ្ជកម្មដែលផ្ទុយនឹងច្បាប់រដ្ឋ ។

ប្រការ ៣ : ប្រកាសនេះ មានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ហត្ថលេខា និង ត្រា

ខៀវ កាញារីទ្ធ

***

រាជធានីភ្នំពេញ , ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៨៩/៩៥ ពម.ប្រក

រដ្ឋមន្ត្រី ក្រសួងពត៌មាន

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជា ណាចក្រកម្ពុជា ចុះថ្ងៃទី ០១-១១-៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល
- យោងលិខិតជូនដំណឹងរបស់ក្រសួងពត៌មាន លេខ ១.២២៤-៩៤ ព.ម ចុះថ្ងៃទី ១៤-១១-៩៤ ស្តីពីការបោះពុម្ពផ្សាយ
- យោងលិខិតស្នើសុំអនុញ្ញាតច្បាប់បើកអាជីវកម្មរោងពុម្ពឈ្មោះ « ច័ន្ទរះ » របស់អ្នកស្រី **មាស ម៉េខន្ធូរ** ចុះថ្ងៃទី ២២ ខែ មករា ឆ្នាំ ១៩៩៥ ។

សំរេច

ប្រការ ១ : អនុញ្ញាតអោយ អ្នកស្រី **មាស ម៉េងហ៊ួរ** ស្ថិតនៅផ្ទះលេខ ៦៩៨ ផ្លូវ ៦ អា សង្កាត់ព្រែកលាប ខ័ណ្ឌ ឫស្សីកែវ រាជធានីភ្នំពេញ បើកអាជីវកម្មដែលមានឈ្មោះ "ច័ន្ទរះ" ស្ថិតនៅទីលំនៅខាងលើ ។

ប្រការ ២ : រាល់ដំណើរការបោះពុម្ពផ្សាយ ត្រូវអនុវត្តតាមកិច្ចសន្យាសមស្របទៅនឹងទំនៀមទំលាប់ សន្តិសុខ សណ្តាប់ធ្នាប់សង្គម និង ច្បាប់របស់ព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣ : ក្នុងករណីប្រព្រឹត្តល្មើស ដូចមានចែងក្នុងប្រការ ២ សាមីខ្លួន នឹងត្រូវទទួលទោសតាមច្បាប់ជាធរមាន ។

ប្រការ ៤ : នាយកដ្ឋានគ្រប់គ្រងការបោះពុម្ពផ្សាយ-សោតទស្សន៍ នៃអគ្គនាយកដ្ឋានរដ្ឋបាល និង ហិរញ្ញវត្ថុ ប្រធានមន្ទីរពត៌មានរាជធានីភ្នំពេញ ត្រូវទទួលអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ។

ប្រការ ៥ : ប្រកាសនេះ មានអានុភាពអនុវត្ត ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ជ.រដ្ឋមន្ត្រី

រដ្ឋលេខាធិការ

ខៀវ កាញារីទ្ធ

* * *

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៩៥

ប្រកាសលេខ ០៩០/៩៥ ពម.ប្រក

ស្តីពីការផ្លាស់ប្តូរកន្លែងធ្វើការ របស់មន្ត្រីរាជការ

-បានឃើញព្រះរាជក្រឹត្យព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម **សីហនុ** វរ្ម័ន ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-យោងការយល់ព្រមរបស់អគ្គនិពន្ធនាយកកាសែតកម្ពុជា ចុះថ្ងៃទី **១៥-០២-៩៥**

-ពិនិត្យលើសំណើសុំផ្លាស់ប្តូរកន្លែងធ្វើការរបស់សាមីខ្លួន

-ពិនិត្យលើតម្រូវការនៃភារកិច្ចចាំបាច់

សំរេច

ប្រការ ១ : យល់ព្រម និង ទទួលស្គាល់មន្ត្រី រាជការចំនួន ០២ នាក់ បំរើការនៅអគ្គនាយកដ្ឋានកាសែតកម្ពុជា ផ្លាស់អោយទៅបំរើការនៅ ទីស្តីការរដ្ឋមន្ត្រីក្រសួងពត៌មាន ដូចមានរាយនាមខាងក្រោម :

១_លោក **ស៊ុន សំនិត** បុគ្គលិកអោយទៅបំរើការនៅនាយកដ្ឋានសារពត៌មាន

២_លោក **ម៉ៅ ផល្លី** អោយទៅបំរើការនៅនាយកដ្ឋាន ផែនការគណនេយ្យ ហិរញ្ញវត្ថុ

ប្រការ ២ : ប្រាក់បៀវត្ស និង ប្រាក់ឧបត្ថម្ភផ្សេងៗរបស់សាមីខ្លួន អគ្គនាយកដ្ឋានកាសែតកម្ពុជា ត្រូវផ្ទេរមក ទីស្តីការរដ្ឋមន្ត្រី ចាប់ពីថ្ងៃទី ១ ខែ ឧសភា ១៩៩៥ នេះតទៅ ។

ប្រការ ៣ : អគ្គនាយកដ្ឋានកាសែតកម្ពុជា នាយកដ្ឋានផែនការគណនេយ្យ ហិរញ្ញវត្ថុ នាយកដ្ឋានបុគ្គលិក និងរដ្ឋបាល និង សាមីខ្លួន មានភារៈអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

អៀង មូលី

* * *

៤. ទីស្តីការរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៣ ខែ មេសា ឆ្នាំ ១៩៩៥

ប្រកាសលេខ ១៤៥ ប្រក កសក ចក
ស្តីពីការផ្ទេរការិយាល័យបូកសរុប ពីមន្ទីរ
ទៅ នាយកដ្ឋានផែនការ ស្ថិតិ

រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា លេខ នស រកត ១០៩៤/៨៣ ចុះថ្ងៃទី ២៤ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការកែសំរួលសមាសភាពរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញអនុក្រឹត្យលេខ ១៨ អនក្រ ចុះថ្ងៃទី ០២ ខែ តុលា ឆ្នាំ ១៩៨៤ ស្តីពីតួនាទីភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងរបស់ក្រសួងកសិកម្ម

-បានឃើញសេចក្តីសំរេចរបស់ក្រសួងកសិកម្ម លេខ ៨៣៦ ចត.កសក ចុះថ្ងៃទី ២៦ ខែ កញ្ញា ឆ្នាំ ១៩៨៦ ស្តីពីតួ នាទីភារកិច្ចនិងរចនាសម្ព័ន្ធចាត់តាំងរបស់មន្ទីរ

-តាមសំណើរបស់ប្រធានមន្ទីរ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

សំរេច

មាត្រា ១ : ផ្ទេរការិយាល័យបូកសរុបរបស់មន្ទីរ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រួមទាំងបុគ្គលិក និងក្របខ័ណ្ឌ ចលនវត្ថុ និង អចលនវត្ថុ ទាំងអស់អោយស្ថិតនៅក្រោមការគ្រប់គ្រង របស់នាយកដ្ឋានផែនការ ស្ថិតិ ។

មាត្រា ២ : បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

មាត្រា ៣ : ប្រធានមន្ទីរ ប្រធាននាយកដ្ឋានផែនការ ស្ថិតិ ប្រធាននាយកដ្ឋាន ចាត់តាំង ប្រធាននាយកដ្ឋាន គណនេយ្យ ហិរញ្ញវត្ថុ និង អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តាវ សេងហួរ

***

៥. លិខិតការរដ្ឋមន្ត្រីក្រសួងពេសចរណ៍

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ១១ ខែ មេសា ឆ្នាំ ១៩៩៥

ប្រកាសលេខ ៤១១ កពច

ស្តីពីការតែងតាំងបន្ថែមជាបណ្តោះអាសន្នចំពោះមន្ត្រី ថ្នាក់អនុប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប

រដ្ឋមន្ត្រី ក្រសួងទេសចរណ៍

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ១៩៩៣ ។

-យោងប្រកាសលេខ ៣៧៥ កទច ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ១៩៩៤ ស្តីពីការបង្កើតរចនាសម្ព័ន្ធថ្នាក់ មន្ទីរ ទេសចរណ៍ខេត្តសៀមរាប-ឧត្តរមានជ័យ ។

-យោងប្រកាសលេខ ០៥ កទច ចុះថ្ងៃទី ២៨ ខែ មករា ឆ្នាំ ១៩៩៥ ស្តីពីការតែងតាំងជាបណ្តោះ អាសន្នចំពោះមន្ត្រី រាជការ និង ក្របខ័ណ្ឌមន្ទីរទេសចរណ៍ខេត្តសៀមរាបឧត្តរមានជ័យ ។

-យោងលិខិតលេខ ០១៣ សណ ចុះថ្ងៃទី ១៤ ខែ មករា ១៩៩៥ របស់អភិបាលខេត្តសៀមរាប ឧត្តរមានជ័យ ស្តីពីការរៀបចំមន្ត្រីរាជការមន្ទីរទេសចរណ៍ខេត្ត ។

-យោងលិខិតលេខ ០៥៦ សណ ចុះថ្ងៃទី ២៨ ខែ មីនា ឆ្នាំ ១៩៩៥ ស្តីពីសំណើសុំតែងតាំង លោក **គឹម នៃហៀង** ជាអនុប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប ។

-យោងតាមសំណូមពរភារកិច្ចចាំបាច់នៃការងារអភិវឌ្ឍន៍ នៅវិស័យទេសចរណ៍ ។

សំរេច

ប្រការ ១ : តែងតាំងបន្ថែម :

លោក **គឹម នៃហៀង** ជាអនុប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប ។

ប្រការ ២ : នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានគ្រប់គ្រងទេសចរណ៍ខេត្ត-ក្រុង ប្រធាននាយកដ្ឋាន គ្រប់គ្រងរដ្ឋបាលទូទៅ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ប្រធានមន្ទីរទេសចរណ៍ខេត្តសៀមរាប និង សាមីខ្លួនត្រូវអនុវត្តតាមប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

វេង សិរីវុឌ្ឍ

៣. ទីស្តីការរដ្ឋមន្ត្រីក្រសួងអប់រំយុវជន និង កីឡា

ប្រកាស

រាជធានីភ្នំពេញ , ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ១៩៩៥

ប្រកាសលេខ ២១៨ អយក.ប្រក
ស្តីពីការផ្តាច់វិទ្យាល័យកលព្រឹក្ស ពី
ឧបសម្ព័ន្ធវិទ្យាល័យគងពិសី ហើយប្តូរឈ្មោះ
វិទ្យាល័យ កលព្រឹក្ស ជាវិទ្យាល័យព្រះ នរោត្តម រណឫទ្ធិ

រដ្ឋមន្ត្រី ក្រសួងអប់រំយុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេច នរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ វិច្ឆិកា ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី ដែលប្រកាសអោយប្រើដោយព្រះរាជក្រម ចុះថ្ងៃទី ២០ កក្កដា ១៩៩៤
- បានឃើញក្រឹត្យច្បាប់លេខ ៣០ ក្រច ចុះថ្ងៃទី ២០ វិច្ឆិកា ១៩៨៦ ស្តីពីប្រព័ន្ធអប់រំចំណេះទូទៅ
- បានឃើញសារាចរណែនាំលេខ ៦៦ អវ.ចទអ ចុះថ្ងៃទី ០២ ខែ មេសា ១៩៨៣ ស្តីពីការបើកសាលាមធ្យមសិក្សាកំរិត ១ កំរិត ២
- យោងលិខិតរបស់មន្ទីរអប់រំយុវជន និងកីឡា ខេត្តកំពង់ស្ពឺលេខ ១៥៥ អយក ចុះថ្ងៃទី ០៥ មេសា ១៩៩៤ ដោយមានយោបល់ឯកភាពពីអភិបាលខេត្តកំពង់ស្ពឺ
- យោងព្រះរាជយោបល់សម្តេចក្រុមព្រះនាយករដ្ឋមន្ត្រីទី ១ និងសំណូមពរព្រះចៅអធិការវត្តជង្រុក

សំរេច

ប្រការ ១ : អនុញ្ញាតអោយផ្តាច់វិទ្យាល័យកលព្រឹក្ស ពីឧបសម្ព័ន្ធវិទ្យាល័យគងពិសី ហើយប្តូរឈ្មោះវិទ្យាល័យកលព្រឹក្សជាវិទ្យាល័យ ព្រះនរោត្តម រណឫទ្ធិ ចាប់ពីឆ្នាំសិក្សា ១៩៩៤-៩៥ តទៅ នៅខេត្តកំពង់ស្ពឺ ។

ប្រការ ២ ៖ វិទ្យាល័យត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ព្រមទាំងបុគ្គលិកផ្សេងៗ ទៀតមួយចំនួន តាមអង្គការលេខ នៃវិទ្យាល័យ ។

ប្រការ ៣ ៖ នាយក-នាយករង នៃវិទ្យាល័យបានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចរបស់នាយក នាយករង នៃវិទ្យាល័យ ។

ប្រការ ៤ ៖ សេចក្តីសំរេចទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះ ត្រូវទុកជាមោឃៈ ។

ប្រការ ៥ ៖ ប្រធានខុទ្ទកាល័យ ប្រធាននាយកដ្ឋានចំណេះទូទៅ និងមត្តេយ្យសិក្សា ប្រធាននាយកដ្ឋានផែនការ-ហិរញ្ញកិច្ច និង ប្រធាននាយកដ្ឋានបុគ្គលិក មានភារកិច្ចរៀងៗខ្លួន អនុវត្តប្រកាសនេះ ។

រដ្ឋមន្ត្រី

ហត្ថលេខា និង ត្រា

តុល ឡោះ

***

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ មេសា ឆ្នាំ ១៩៩៥

សេចក្តីសំរេចលេខ ២៣២ អយក.ប្រក
